ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

260 season
357

សាលាឧទ្ធរណ៍ព្រះសីហនុ

សំណុំរឿងសភាព្រហ្មទណ្ឌ
លេខ:០០៩/២៧-១០-២០២០
សាលដីកា
លេខ:០០៣/០០១"ក្រ.l.ព្រ.ទ"
ចុះថ្ងៃទី១៧-១២-២០២០

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ព្រះសីហនុ

សភាព្រហ្មទណ្ឌបង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍ព្រះសីហនុ នាព្រឹកថ្ងៃព្រហស្បតិ៍ ៣ រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ ដោយមាន៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សា
ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម យូ ឆិត្យបឌ្ឍនៈ អគ្គព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីពិភាក្សាជេញដោលលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងសភាព្រហ្មទណ្ឌលេខ: ០០៩ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ដែលមាន ៖

១-ជនជាប់ចោទ [redacted] HAO ភេទប្រុស កើតឆ្នាំ១៩៩០ ជនជាតិចិន មុខរបរ ចូលហ៊ុនបើកផ្សារ និងផ្ទះសំណាក់ មានទីកន្លែងកំណើតនៅ ខេត្តហ្វូជៀង ប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួននៅ [redacted] ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] QUA មានកូនចំនួន០១នាក់ ឪពុកឈ្មោះ [redacted]" ម្តាយឈ្មោះ [redacted]" ជានីតិជនទោសពីមុនគ្មាន។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៦២២ ត.៣/១៩ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩)

-មានមេធាវី [redacted]ស៊ីណា ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] HAO ។

២-ជនជាប់ចោទឈ្មោះ [redacted] PI ភេទស្រី កើតឆ្នាំ១៩៨០ ជនជាតិចិន មុខរបរ អ្នកគួបជេរដី និងផ្ទះ ហានទីកន្លែងកំណើតនៅ ខេត្ត គ័ងទង់ ប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួននៅជិតផ្សារលើ ស[redacted] ឪពុកឈ្មោះ [redacted]"ៗ" ម្តាយឈ្មោះ [redacted]"ៗ" មេម៉ាយ មានកូនចំនួន០២នាក់ ជានីតិជន ទោសពីមុនគ្មាន។

101/15

ជាប់ចោទពីបទៈ សមគំនិតក្នុងអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុម៤ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

៣-ជនជាប់ចោទឈ្មោះ [redacted] GUO ភេទប្រុស កើតឆ្នាំ១៩៧៧ ជនជាតិចិន មុខរបរជាងសំណង់ មានទីកន្លែងកំណើតនៅ ប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួននៅ[redacted]នុ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted]ានកូនចំនួន០២នាក់ ឪពុកឈ្មោះ [redacted]រ" ម្តាយឈ្មោះ [redacted] "រ" ជានីតិជន ទោសពីមុនគ្មាន។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៧៩១ គ.ព/១៩ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩)

៤-ជនជាប់ចោទឈ្មោ[redacted] DONG ភេទប្រុស កើតឆ្នាំ១៩៨៤ ជនជាតិចិន មុខរបរជាងសំណង់ មានទីកន្លែងកំណើតនៅប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួននៅ[redacted] ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០៤នាក់ ឪពុកឈ្មោះ [redacted]"រ" ម្តាយឈ្មោះ [redacted]"រ" ជានីតិជន ទោសពីមុនគ្មាន។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៧៩៣ គ.ព /១៩ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩)

មានមេធាវីឈ្មោះ [redacted] ច័ន្ទពិសិដ្ឋ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

៥-ជនជាប់ចោទឈ្មោះ [redacted] XINHAI ភេទប្រុស កើតឆ្នាំ១៩៨៨ ជនជាតិចិន មុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើតនៅខេត្តYUNNAN ប្រទេសចិន មានទីលំនៅបច្ចុប្បន្ននៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាន់លិខិតឆ្លងដែនលេខ EC9816583។ (ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១០៧ /១៩ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩)

ជាប់ចោទពីបទៈ ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុម៤ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ម្ចាស់បណ្តឹងឧទ្ធរណ៍ឈ្មោះ [redacted]HAO និងឈ្មោះ [redacted]DONG ជាជនជាប់ចោទ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង១១ និង១៥ នាទី ស្ថិតនៅចំណុចផ្ទះសំណាក់ព្រីនសេស ក្នុងក្រុមទី៤ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន,រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងសមគំនិតក្នុងអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនមួយកើតឡើង ដែលផ្តើមចេញពីករណីអគ្គីភ័យនៅចំណុចខាងលើនៅពេលសមត្ថកិច្ចចូលទៅពន្លត់ និងត្រួតពិនិត្យតាមបន្ទប់នីមួយៗដែលបានរងការខូចខាតដោយអគ្គីភ័យ ឃើញថាបន្ទប់លេខ C៣៦ មានសំណាកសង្ស័យចំនួន ០២ ដុំ រួមមាន ថ្នាំគ្រាប់ WY ចំនួន ៥០ ដុំ មានចំនួន ៣០០,០០០ គ្រាប់ ទម្ងន់ ២៧,៥៤៣ ក្រាម និងម្សៅក្រាមពណ៌សថ្លាជាសារធាតុញៀនប្រភេទកេតាមីនមួយកញ្ចប់ធំ ចំនួន ១,០៤៧,៣៦ ក្រាម (ថ្លឹងទាំងសំបក) ហើយសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យពីរនាក់ទៀតឈ្មោះ [redacted] HAO ភេទប្រុស ជនជាតិចិន និងឈ្មោះ [redacted] PI ភេទស្រី ជនជាតិចិន ដោយពួកគេបានសារភាពថាម្ចាស់ បន្ទប់លេខ C៣៦ មានឈ្មោះ [redacted] XINHAI ភេទប្រុស ជនជាតិ

ចិន។ ក្រោយមកនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ កម្លាំងនគរបាលព្រហ្មទណ្ឌកម្រិតស្រាលបានបង្ក្រាប និងឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់។មានឈ្មោះ [redacted] DONG ភេទប្រុស ជនជាតិចិន និង ឈ្មោ[redacted]UO ភេទប្រុស ជនជាតិចិន ពាក់ព័ន្ធនឹងករណីប្រើប្រាស់អាវុធខុសច្បាប់ដោយឆែកឆេរ រកឃើញគ្រឿងញៀនម្សៅក្រាមសថ្លាចំនួន ០១ កញ្ចប់ធំ និងថ្នាំគ្រាប់ WY ចំនួន ០៦ កញ្ចប់ នៅក្នុងកាបូបស្ពាយចំហៀងរបស់ឈ្មោះ [redacted]DONG ដោយពួកគេបានបញ្ជាក់ថាគ្រឿងញៀនដែលសមត្ថកិច្ចដកហូតបាននោះគឺជារបស់ឈ្មោះ[redacted] XINHAI ភេទប្រុស ជនជាតិចិន ដែលជាម្ចាស់ បន្ទប់លេខ C៣៦ ដែលត្រូវភ្លើងឆេះនោះ ហើយចំណុចនេះនាំឱ្យសមត្ថកិច្ចជំនាញសន្និដ្ឋានថា ជនសង្ស័យឈ្មោះ [redacted] XINHAI ភេទប្រុស ជនជាតិចិន,ឈ្មោះ [redacted]DONG ភេទប្រុស ជនជាតិចិន និងឈ្មោះ[redacted] DUO ភេទប្រុស ជនជាតិចិន គឺជាបក្ខពួកតែមួយ។

**បានឃើញ** សាលក្រមលេខ: ៨៦៥/៩៨ (យ) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted]HAO ។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] DONG ។

**បានឃើញ** របាយការណ៍ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ព្រះសីហនុ ។

**បានឃើញ** សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ។

## នាពេលពិភាក្សាដេញដោល

-ជនជាប់ចោទឈ្មោះ[redacted]HAO (វត្តមាន)

-ជនជាប់ចោទឈ្មោះ[redacted] DONG (វត្តមាន)

-ឈ្មោ[redacted]ស៊ីណា ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] HAO (វត្តមាន)

-ឈ្មោះ គីម ច័ន្ទពិសិដ្ឋ ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] DONG (វត្តមាន)

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍អំពីរឿងក្តី ។

-ជនជាប់ចោទឈ្មោះ [redacted]DONG បានឆ្លើយថា៖ មូលហេតុខ្លួនប្តឹងឧទ្ធរណ៍ ដោយសារខ្លួនមិនដឹងរឿងអ្វីទាំងអស់។ ខ្លួនមិនបានពាក់ព័ន្ធនឹងរឿងនេះទេ សុំឱ្យតុលាការដោះលែង។ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ថ្ងៃកើតហេតុ ប៉ុន្តែខ្លួននៅស្នងការហៅនៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយសារបងខ្លួន និងបងថ្លៃឈ្លោះគ្នា ដោយមានរឿងបាញ់កាំភ្លើង បងថ្លៃអ្នកបាញ់។ នៅថ្ងៃកើតហេតុ ខ្លួនមិនបានដឹងអ្វីនោះទេ ហើយខ្លួនក៏មិនបានទៅនោះដែរ។បានជាសមត្ថកិច្ចឃាត់ខ្លួន ដោយសារបង និងបងថ្លៃខ្លួនឈ្លោះគ្នា ពេលនោះបងថ្លៃឈ្មោះ XINHAI ទាញកាបូបរកវាយបងខ្លួន ទើបខ្លួនទាញកាបូបនោះ។ កាបូបនោះមានគ្រឿងញៀនតែមិនមែនជារបស់ខ្លួនទេ គឺជារបស់បងថ្លៃឈ្មោះ XIN HAI ហើយខ្លួនក៏មិនបានដឹងថាមានគ្រឿងញៀននោះទេ សមត្ថកិច្ចឃាត់ខ្លួននៅក្នុងបន្ទប់ផ្ទះសំណាក់ផ្សេង មិនមែននៅទីតាំងផ្ទះសំណាក់កើតហេតុទេ។ សាលាដំបូងខេត្តព្រះសីហនុ បានសម្រេចផ្តន្ទាទោសចំនួន ០៥ ឆ្នាំ រួចមកហើយ ពាក់ព័ន្ធនឹងករណី

កាបូបមានគ្រឿងញៀន នៅវង្សមូលគ្រីដូនហ្វីន។ ឈ្មោះ XIN HAI គ្រាន់តែជាបងថ្លៃខ្លួន ខ្លួនមិនបានរកស៊ីអ្វីជាមួយគាត់ទេ។

-ជនជាប់ចោទឈ្មោះ[redacted] HAO បានឆ្លើយថា៖ ថ្ងៃកើតហេតុ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ខ្លួនបានគេប្រាប់សមត្ថកិច្ច ពេលនោះសមត្ថកិច្ចបានធ្វើកំណត់ហេតុនៃការខូតខាតចូលតាមបន្ទប់នីមួយៗ ស្រាប់តែចូលទៅបន្ទប់C៣៦ ក៏ប្រទះឃើញថង់ខ្មៅចំនួន០២ ដុំ។ ពេលដែលឆេះនោះគឺបន្ទប់C៣៦ ពេលនោះខ្លួនមិនដឹងថាមានមនុស្សទេ ហើយបន្ទប់នឹងខ្លួនបានជួលឱ្យទៅឈ្មោះ[redacted] អ៊ី នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩ ការធ្វើកិច្ចសន្យានោះខ្លួនមិនបានធ្វើនោះទេ គឺឈ្មោះ [redacted]ហ្វាង ជាអ្នកធ្វើតុងត្រាការជួលតម្លៃ ៣០០ ដុល្លារអាមេរិក ក្នុងមួយខែ ជួលរយៈពេល៦ខែ។ ខ្លួនមិនមែនជាអ្នកគ្រប់គ្រងនោះ គ្រាន់តែមកមើលមួយភ្លែតៗទេ ។ឈ្មោះ[redacted]អ៊ី មិនស្គាល់នោះទេ ស្គាល់តាមរយៈអ្នកគួកជេរជាអ្នកនាំមក អ្នកគួកជេរ នោះគឺជាជនជាតិចិន មិនមែនជាសាច់ញាតិនោះទេ។ ឈ្មោ[redacted]អ៊ី និងឈ្មោះ [redacted] HAI ជាមនុស្សតែមួយ នៅពេលមកជួលដាក់ឈ្មោះ [redacted]អ៊ី ពេលដល់សមត្ថកិច្ចដាក់ឈ្មោះ [redacted] HAI វិញ។ មានកាមេរ៉ា នៅក្នុងផ្ទះសំណាក់ជួនកាលដំណើរ ជួនកាលមិនដំណើរការ ហើយថ្ងៃដែលជួលនោះខ្លួនមិនបានមើលទេ។ ពេលដែលភ្លើងឆេះនឹងខ្លួនមិនដឹងទេពីមូលហេតុថាឆេះមកពីអ្វី ហើយខ្លួនបានទៅគេប្រាប់សមត្ថកិច្ច។ ឈ្មោះ [redacted] PI ជាអ្នកគួបជេរ ពេលជួលរួចខ្លួនបានឱ្យប្រាក់ជើងសារចំនួន ១៨០ ដុល្លារអាមេរិក។ នៅពេលភ្លើងឆេះខ្លួនបានគេទៅអ្នកគួកជេរឱ្យទំនាក់ទំនងអ្នកជួល ពេលកើតហេតុខ្លួនបានប្រមូលបុគ្គលិកមកជួយពន្លត់ភ្លើង បន្តិចក្រោយមកទើបសមត្ថកិច្ចមកដល់ ក្នុងពេលដែលឆេះខ្លួនក៏បានជួយពន្លត់ និងបានចូលរួមជាមួយសមត្ថកិច្ចធ្វើកំណត់ហេតុ។ ភ្លើងឆេះក្នុងម៉ោង ដប់ ព្រឹក ហើយសមត្ថកិច្ចមកដល់ប្រហែលជា ១៥ ទៅ ២០នាទី។ នៅពេលដែលឆេះបន្ទប់មានអ្នកស្នាក់នៅជិតបន្ទប់មកប្រាប់ អ្នកដែលហៅនោះគឺជនជាតិចិន ពេលនោះខ្លួនកំពុងនៅក្នុងបន្ទប់ វី សិប ទើបប្រមូលគ្នាទៅពន្លត់ ដោយនាំគ្នាធាក់ទ្វាចូលដោយសារភ្លើងឆេះ។ បន្ទប់លេខC៣៦ ខ្លួនមិនដឹងជាទ្វានោះចាក់ ឬមិនចាក់សោរនោះទេ ខ្លួនបានជួបឈ្មោះ[redacted]HAI បានពែម្តងនៅពេលគាត់បង់ប្រាក់ជួល ៣០០ ដុល្លារអាមេរិក។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានធ្វើការពិភាក្សាដេញដោលតំណាងមហាអយ្យការយល់ឃើញថា ពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ[redacted]DONG គឺមានការប្រទាក់ក្រឡាតាំងពីថ្ងៃទី០២ និងថ្ងៃទី០៣ មានន័យថា នៅថ្ងៃទី២ សមត្ថកិច្ចបានឃាត់ខ្លួន ជាប់ជាមួយនឹងវត្ថុតាងថ្នាំញៀនមួយកាបូប ហើយខ្លួនក៏បានសារភាពថា ខ្លួនត្រូវបានសាលាដំបូងខេត្តព្រះសីហនុ ផ្តន្ទាទោសចំនួន ០៥ ឆ្នាំ រួចហើយ។ ម្យ៉ាងទៀតពាក់ព័ន្ធនឹងឈ្មោះ[redacted] HAI គឺជាបងថ្លៃថ្លៃរបស់ឈ្មោ[redacted] DONG តាមការពិនិត្យលើកោសវិច្ច័យរបស់សមត្ថកិច្ចឃើញថាគ្រឿងញៀនដែលចាប់នៅថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០១៩ និងគ្រឿងញៀនដែលឈ្មោះ [redacted] HAI ដាក់ក្នុងបន្ទប់ C៣៦ ជាប្រភេទ ថ្នាំញៀនដូចគ្នា ឃើញថា [redacted] DONG និងឈ្មោះ [redacted]HAI គឺជាបក្សពួកតែមួយ។ ចំពោះ [redacted] HAO គឺមានភាគហ៊ុនក្នុងសណ្ឋាគារព្រីនសេស ចំនួន៣០ ភាគរយ ហើយ ខ្លួនថាមិនបានពាក់ព័ន្ធ ឃើញថាក្នុងរយៈពេល៣ ថ្ងៃ គ្រឿញៀនចំនួន ៣០ គីឡូ បើមិនមានការសម្រួលពីម្ចាស់សណ្ឋាគារទេគឺគ្រឿងញៀនចូលមិនស្រួលទេ។ ម្យ៉ាងទៀតពាក់ព័ន្ធនឹងថាខ្លួនមិនពាក់ព័ន្ធពុំមានភស្តុតាងណាបញ្ជាក់ថាមិនពាក់ព័ន្ធនឹងហេតុ សូម្បីតែកាមេរ៉ារបស់ខ្លួនក៏ខូច ហេតុដូច្នេះតំណាងមហាអយ្យការ គិតថាឈ្មោះ[redacted] HAO ជាប់ពាក់ព័ន្ធនឹងការសម្រួលដល់ការសមគំនិតក្នុងការរក្សាទុកនូវសារធាតុញៀន ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលក្រមទុកជាបានការដដែល។

-មេធាវី [redacted] ស៊ីណា ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] HAO បានធ្វើសេចក្តីសន្និដ្ឋានថាៈ ពាក់ព័ន្ធនឹងរឿងកូនក្តីខ្លួន គ្រាន់តែមានភាគហ៊ុនតូចមួយ ហើយកូនក្តីខ្លួនមិនមែនជាអ្នកគ្រប់គ្រងនោះទេគឺឈ្មោះ សូ ផុងហ្វាង ជាអ្នកគ្រប់គ្រង ។ កូនក្តីខ្លួនបានដកប្រាក់ចំនួន១៨០ ដុល្លារឱ្យទៅឈ្មោះ សេវ ជា ដែលជាអ្នកនាំមក។ ក្រោយពីបានដកប្រាក់ឱ្យហើយកូនក្តីខ្លួនបានចេញទៅក្រៅវិញហើយ ទុក ឱ្យអ្នកគ្រប់គ្រងនៅទីនោះចាត់ចែងបន្ត។ ចំពោះទីតាំងផ្ទះសំណាកព្រីនសេស គឺមានកាំជណ្តើរនៅខាងមុខ ហើយកន្លែង វី សិប គឺនៅខាងក្នុងអាចឡើងទៅខាងលើបានដោយមិនចាំបាច់ឆ្លងកាត់កន្លែង វី សិប ស្រាប់តែឃើញអ្នកជួលឡើងទៅកូនក្តីខ្លួនបានឡើងទៅតាម ហើយសួរថា មកនៅហើយឬ រួចហើយក៏ចប់គ្នាទៅ។ នៅថ្ងៃកើតហេតុកូនក្តីខ្លួនបានដឹងថាភ្លើងឆេះបន្ទប់C៣៦ ពីអ្នកជិតខាងប្រាប់ ហើយក៏នាំគ្នាទៅពន្លត់ សូមបញ្ជាក់ថា បន្ទប់នោះបិទ។ មូលហេតុដែលឆេះនោះគឺវិមតិសង្ស័យដែលសមត្ថកិច្ចមិនបានបញ្ជាក់ថា ភ្លើងឆេះពីកន្លែងណា វាជាវិមតិសង្ស័យមួយដែលពុំមានភស្តុតាង។ កូនក្តីខ្លួនមិនមានគោលបំណងជួលបន្ទប់ ឱ្យដាក់គ្រឿងញៀននោះទេ ប្រសិនបើកូនក្តីខ្លួនដឹងថាបន្ទប់នោះមានគ្រឿងញៀន គឺប្រាកដជារត់បាត់ហើយ ដូចនេះឃើញថាពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ទេ។ កូនក្តីខ្លួនប្រកបអាជីវកម្មគោលបំណងចង់បានតែប្រាក់ឈ្នួលទេ មិនចង់បានអ្វីលើសពីប្រាក់ឈ្នួលនោះទេ រាល់ការចោទប្រកាន់ដែលកើតចេញពីវិមតិសង្ស័យ សុំតុលាការមេត្តាផលនូវភាពអនុគ្រោះផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ និងសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ និងដោះលែងឱ្យមានសេរីភាពឡើងវិញ។

-មេធាវី [redacted] ច័ន្ទពិសិដ្ឋ ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] DONG បានធ្វើសេចក្តីសន្និដ្ឋានថាៈ សុំធ្វើសេចក្តីសន្និដ្ឋានសង្ខេបៗចំនួន៣ ទី១ តាមការសិក្សាសំណុំរឿង ការស្តាប់ចម្លើយជនជាប់ចោទ យល់ឃើញថាពុំមានភស្តុតាងសមត្ថកិច្ចកសាងមកបញ្ជាក់ថាគ្រឿងញៀននៅសណ្ឋាគារព្រីនសេស នោះមិនមែនជារបស់កូនក្តីខ្លួនឡើយ ទី២ តាមរយៈចម្លើយរបស់ឈ្មោះ [redacted] PI ជាអ្នកឌួកដេរនាំឈ្មោះ [redacted] HAI បានបញ្ជាក់នៅសាលាដំបូងថាគឺមិនស្គាល់ឈ្មោះ [redacted] DONG នោះទេ គ្រឿងញៀននោះជារបស់ឈ្មោះ [redacted] HAI ប៉ុណ្ណោះ ទី៣ ហេតុអ្វីរបាយការណ៍របស់សមត្ថកិច្ចបញ្ចូលកូនក្តីខ្លួនចូលទៅក្នុងសំណុំរឿងនេះ ដោយគ្មានមូលហេតុច្បាស់លាស់។ ករណីគ្រឿងញៀននៅសណ្ឋាគារព្រីនសេស គឺកើតហេតុនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ កូនក្តីខ្លួនត្រូវបានឃាត់ ខ្លួននៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ពាក់ព័ន្ធករណីរើសកាបូបនៅវង់មូលត្រីដូងហ្វីន កូនក្តីខ្លួនត្រូវបានតុលាការផ្តន្ទាទោសចំនួន ០៥ ឆ្នាំរួចមកហើយ។ យោងតាមមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌបានចែងថា បុគ្គលម្នាក់ៗទទួលខុសត្រូវទៅលើអំពើរបស់ខ្លួន។ ពាក់ព័ន្ធករណីគ្រឿងញៀននៅសណ្ឋាគារព្រីនសេសកូនក្តីខ្លួនមិនបានដឹងនោះទេ ហេតុដូច្នេះសុំក្រុមប្រឹក្សាមេត្តាពិចារណាមាត្រានេះ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានចែងអំពីវិមតិសង្ស័យបានជាប្រយោជន៍របស់ជនជាប់ចោទ ដូច្នេះស្នើសុំកូនក្តីខ្លួនរួចផុតពីបទចោទក្នុងករណីគ្រឿងញៀននៅសណ្ឋាគារព្រីសេសនេះផង។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សភាព្រហ្មទណ្ឌយល់ឃើញថា:

១-ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] HAO និងពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] DONG សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ៨៦៥/៩៩ (ឃ) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ គឺមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ព្រះសីហនុអាចទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា ៣៧៥ និងមាត្រា ៣៨២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧, មាត្រា ៣៦៨, មាត្រា ៣៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទឈ្មោះ [redacted] DONG បានឆ្លើយថា ខ្លួនមិនបានដឹងរឿងអ្វីទាំងអស់ក្នុងករណីនឹងគ្រឿងញៀននៅសណ្ឋាគារព្រីនសេស សមត្ថកិច្ចបានឃាត់ខ្លួននៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ពាក់ព័ន្ធកាបូបដែលមានគ្រឿងញៀននៅម្តុំរង្វង់មូលត្រីដូហ្វីន ហើយត្រូវបានសាលាដំបូងខេត្តព្រះសីហនុ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន០៥ ឆ្នាំ រួចមកហើយ ថែមទាំងបញ្ជាក់ឈ្មោះ [redacted] HAI ជាបងថ្លៃរបស់ខ្លួន ហើយគ្រឿងញៀនដែលដកហូតបាននៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ ឈ្មោះ [redacted] DONG បានឆ្លើយថាគឺជារបស់ឈ្មោះ [redacted] HAI និងបើតាមការបញ្ជាក់របស់សមត្ថកិច្ចបានឱ្យដឹងថា គ្រឿងញៀនដែលហូតដកបានពីជនជាប់ចោទឈ្មោះ [redacted] X[redacted] DONG និងគ្រឿងញៀនដែលនៅក្នុងសណ្ឋាគារព្រីនសេសជារបស់ឈ្មោះ [redacted] HAI គឺជាប្រភេទញៀនដូចគ្នា ដូច្នេះពួកគេគឺជាបក្សពួកតែមួយ ជនជាប់ចោទឈ្មោះ [redacted] DONG ពិតជាមានការជាប់ពាក់ព័ន្ធនឹងករណីគ្រឿងញៀននៅសណ្ឋាគារព្រីនសេសប្រាកដមែន។

៣-ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទឈ្មោះ [redacted] HAO បានឆ្លើយថា នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ ថ្ងៃកើតហេតុ វេលាម៉ោងប្រហែល ១០ ព្រឹក មានអ្នកជិតខាងបានមកប្រាប់ថាបន្ទប់ C៣៦ ត្រូវភ្លើងឆេះ ភ្លាមនោះខ្លួនបានឱ្យបុគ្គលិកគេប្រាប់សមត្ថកិច្ច និងបាននាំគ្នាទៅពន្លត់ភ្លើង ប្រហែលជា ១៥ ទៅ ២០នាទី សមត្ថកិច្ចមកដល់ ខ្លួនក៏បានចូលរួមជួយជាមួយសមត្ថកិច្ច បន្ទាប់ពីពន្លត់ភ្លើងរួចខ្លួនបានចូលរួមធ្វើកំណត់ហេតុនៃការខូចខាតជាមួយសមត្ថកិច្ចផងដែរ មិនបានរត់គេចទៅណាទេ ចំពោះភ្លើងឆេះនេះខ្លួនក៏មិនដឹងមូលហេតុថាឆេះមកពីអ្វីដែល ។ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] HAO គ្រាន់តែជាអ្នករកស៊ីម្នាក់ដែលមានភាគហ៊ុន៣០ ភាគរយ ក្នុងសណ្ឋាគារព្រីនសេស ហើយក៏មិនមែនជាអ្នកគ្រប់គ្រងនៅទីនោះដែរ ។ តាមចម្លើយរបស់ឈ្មោះ [redacted] PI បានឆ្លើយថា ឈ្មោះ [redacted] HAO និងឈ្មោះ [redacted] HAI គឺមិនដែលស្គាល់គ្នាពីមុនមកទេ ហើយនៅពេលដែលមានភ្លើងឆេះនោះគឺឈ្មោះ [redacted] HAO បានទូរស័ព្ទមកខ្លួនឱ្យទំនាក់ទំនងទៅឈ្មោះ [redacted] HAI ដែលជាអ្នកជួលដែលខ្លួននាំមករំពីភ្លើងឆេះ បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] HAO មិនមានអ្វីទំនាក់ទងជាមួយនឹងឈ្មោះ [redacted]AI នោះដែរ។

៤-ចំពោះមូលហេតុនៃការឆេះបន្ទប់ C៣៦ នៅសណ្ឋាគារព្រីនសេសសមត្ថកិច្ចមិនបានបញ្ជាក់ឱ្យច្បាស់ថាឆេះពីកន្លែងណាមួយ ឬឆេះបណ្តាលមកពីអ្វីមួយឱ្យបានច្បាស់លាស់នោះទេ វាជាវិមតិសង្ស័យមួយ ម្យ៉ាងទៀតកាមេរ៉ាសុវត្ថិភាពនៅក្នុងសណ្ឋាគារព្រីនសេសមិនដំណើរមិនអាចមើលបាន ដែលពុំមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] HAO។

៥-តាមការបញ្ជាក់របស់ជនជាប់ចោទឈ្មោះ [redacted] HAO បានឱ្យដឹងថា ឈ្មោះ [redacted] និង ឈ្មោះ [redacted] HAI ជាមនុស្សតែមួយ។

៦-សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ សភាព្រហ្មទណ្ឌលើកយកមកពិចារណារួចហើយ ។

៧-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] HAO បានលើកឡើងថា កូនក្តីខ្លួនប្រកបរបរអាជីវកម្មគោលបំណងចង់បានតែ ប្រាក់ឈ្នួលទេ មិនចង់បានអ្វីលើសពីប្រាក់ឈ្នួលនោះទេ រាល់ការចោទប្រកាន់ដែលកើតចេញពីវិមតិសង្ស័យ សុំតុលាការមេត្តាផល់នូវភាពអនុគ្រោះផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ និងសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ និងដោះលែងឱ្យមានសេរីភាពឡើងវិញ សភាព្រហ្មទណ្ឌបានលើកយកមកពិចារណារួចហើយ។

៨-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] DONG បានលើកឡើងថា ពាក់ព័ន្ធករណីរវើសកាបូបនៅរង្វង់មូលត្រីដូងហ្វីន កូនក្តីខ្លួនត្រូវបាន តុលាការផ្តន្ទាទោសចំនួន ០៥ ឆ្នាំរួចមកហើយ។ យោងតាមមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ គោលការណ៍ ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌបានចែងថា បុគ្គលម្នាក់ៗទទួលខុសត្រូវទៅលើអំពើរបស់ខ្លួន។ ពាក់ព័ន្ធករណីគ្រឿងញៀននៅសណ្ឋាគារព្រីនសេសកូនកក្តីខ្លួនមិនបានដឹងនោះទេ ហេតុដូច្នេះសុំក្រុមប្រឹក្សាមេត្តាពិចារណាមាត្រានេះ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានចែងអំពីវិមតិសង្ស័យបានជាប្រយោជន៍របស់ជនជាប់ចោទ ដូច្នេះស្នើសុំកូនក្តីខ្លួនរួចផុតពីបទចោទក្នុងករណីគ្រឿងញៀននៅសណ្ឋាគារព្រីសេសនេះផង សភាព្រហ្មទណ្ឌបានលើកយកមកពិចារណារួចហើយ។

៩-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ យល់ឃើញថា៖

-ជនចោទឈ្មោះ [redacted] HAO ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ពីបទ៖ សមគំនិតក្នុងអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុមទី៤ ភូមិ៣ សង្កាត់លេខ ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ឡើយ ដោយហេតុថាឈ្មោះ [redacted] HAO ពុំមានចេតនាទុច្ចរិតណាមួយក្នុងការជួលបន្ទប់ឱ្យឈ្មោះ [redacted] HAI សម្រាប់ដាក់គ្រឿងញៀននោះទេ ។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] HAO បានចូលរួមសហការជាមួយនឹងសមត្ថកិច្ចក្នុងការពន្លត់អគ្គីភ័យ និងចូលរួមធ្វើកំណត់ហេតុតាំងពីដើមរហូតដល់ចប់ ម្យ៉ាងទៀតប្រសិនបើឈ្មោះ [redacted] HAO ដឹងថាបន្ទប់C៣៦ មានគ្រឿងញៀន ហើយត្រូវបានភ្លើងឆេះខ្លួនប្រាកដជារត់គេចខ្លួនពីកន្លែងកើតហេតុបាត់ហើយ។ ក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យឈ្មោះ [redacted] HAO រួចខ្លួនពីបទចោទ ពីបទ សមគំនិតក្នុងអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនតាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] DONG ភេទប្រុស កើតឆ្នាំ ១៩៨៤ ពីបទ ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុមទី៤ ភូមិ៣ សង្កាត់លេខ ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

101/9

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] HAO ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ និងពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] DONG ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៦៥/៩៨ (ឃ) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល លើកលែងតែ ចំណុចទី២ (២.ក) ត្រូវបានកែប្រែ និងសម្រេចជាថ្មីដូចខាងក្រោម៖

-ឱ្យឈ្មោះ [redacted] HAO រួចខ្លួនពីបទចោទ ពីបទ សមគំនិតក្នុងអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅនៅក្រុមទី៤ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

សាលដីកានេះបើកសវនាការជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ៣ រោច ខែមិគសិរ ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ៣ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] HAO និងឈ្មោះ [redacted] DONG។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា

[redacted] [redacted] [redacted] [redacted]



Scanned with CamScanner